# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែឧសភា-មិថុនា ឆ្នាំ២០១៧**

**May - June 2017**

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៨ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១០ |
| ១.៧. វិស័យសំណង់ / Construction | ១១ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១១** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១២ |
| **៣. ឧបសម្ព័ន្ធ** | **១៣** |

## ខ្លឹមសារសង្ខេប

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែឧសភា ឆ្នាំ២០១៧ បានថយចុះ ០,២% ធៀបនឹងខែមេសាកន្លងទៅ ប៉ុន្តែបានកើនឡើង ២,៥% បើធៀបនឹង១ឆ្នាំមុន។ ក្នុងខែឧសភានេះ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញស្ទើរតែទាំងអស់បានថយចុះធៀបនឹងខែមុន លើកលែងតែសន្ទស្សន៍ថ្លៃភោជនីយដ្ឋានដែលមានការកើនឡើង ២,៨%។ បើធៀបនឹង១ឆ្នាំមុន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បានកើនឡើង ២,៥% ក្នុងនោះសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងកើនឡើង ២,៩% ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើនឡើង ១,៧% សម្លៀកបំពាក់និងស្បែកជើងកើនឡើង ២,៩% និងការដឹកជញ្ជូនកើនឡើង ៤,០%។ តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ(year on year) អាចមានអត្រា ២,២% ឬអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ៣,១%។

២. *ឥណទាន និងអត្រាការប្រាក់៖* ក្នុងខែឧសភា ឆ្នាំ២០១៧នេះ ឥណទានផ្តល់ដោយធនាគារពាណិជ្ជបានកើនឡើង ១,៧% ធៀបនឹងខែមុន (កើនឡើង ១១,៤% ធៀបនឹង១ឆ្នាំមុន), ក្នុងនោះឥណទានផ្តល់ដល់វិស័យសេវាកម្មបានកើនឡើង ០,៩%, ឥណទានវិស័យកសិកម្មបានកើនឡើង ១,២%, ប៉ុន្តែឥណទានវិស័យឧស្សាហកម្មបានថយចុះ ០,៨%, រីឯឥណទានផ្តល់ដល់របរនីត្តបុគ្គលនិងផ្សេងៗបានបន្តកើនឡើងខ្ពស់ក្នុងខែឧសភានេះ។ អត្រាការប្រាក់ឥណទានរបស់ធនាគារពាណិជ្ជមាននិន្នាការថយចុះគួរកត់សម្គាល់ក្នុងរយៈពេល៤ខែដើមឆ្នាំ២០១៧នេះ, គិតត្រឹមខែមេសា អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះឥណទានជាប្រាក់រៀលស្មើ ១៤,៨៤% និងឥណទានជាប្រាក់ដុល្លារស្មើ ១១,៦៤%។ តាមការសង្កេត អត្រាការប្រាក់ឥណទាននៅកម្ពុជាខ្ពស់ជាងប្រទេសជិតខាងក្នុងតំបន់, តាមប្រភពពីធនាគារពិភពលោក នៅឆ្នាំ២០១៦ អត្រាការប្រាក់ឥណទាននៅប្រទេសថៃស្មើ៦,៣% វៀតណាម៧,០% ហ្វីលីពីន៥,៦% មីយ៉ាន់ម៉ា១៣,០% និងនៅកម្ពុជា១១,៩% (ចំពោះប្រាក់ដុល្លារ)។ អត្រាការប្រាក់នៅវៀតណាមបានថយចុះយ៉ាងខ្លាំងក្នុងរយៈពេល៦ឆ្នាំចុងក្រោយនេះ ដោយសារមានវិធានការបន្ធូរអត្រាការប្រាក់ពីធនាគារកណ្តាលជាបន្តបន្ទាប់ដើម្បីស្តារសេដ្ឋកិច្ច។

*ការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាប្តូរប្រាក់៖* គិតត្រឹមខែឧសភា រូបិយវត្ថុទូទៅM2 មានចំនួន ៦២.៩២១ប៊ីលានរៀល បានកើនឡើង ១,៩% ធៀបនឹងខែមុន និងបានកើនឡើង ១៨,០% ធៀបនឹង១ឆ្នាំមុន ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានកើនឡើង ១,៥% ធៀបនឹងខែមុន និងបានកើនឡើង ១៨,០% ធៀបនឹង១ឆ្នាំមុន។ ប្រាក់រៀលបានថយចុះតម្លៃបន្តិចម្តងៗគិតចាប់ពីខែមីនាមក, គិតត្រឹមខែមិថុនា ឆ្នាំ២០១៧ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤.០៨៦រៀល/ដុល្លារ និងអត្រាខែមីនាស្មើនឹង ៤.០០៥រៀល/ដុល្លារ។ ធនាគារជាតិកម្ពុជាអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ធនាគារជាតិបានទិញចូលរូបិយប័ណ្ណដុល្លារអាមេរិកជាច្រើន ប្រមាណជិត ៨០០លានដុល្លារក្នុង១ឆ្នាំៗ ទន្ទឹមនឹងនេះប្រាក់ទុនបំរុងជារូបិយប័ណ្ណបរទេសក៏មានកំណើនឡើងខ្ពស់គួរកត់សម្គាល់ផងដែរ, ប៉ុន្តែក្នុងត្រីមាសទី១ ដើមឆ្នាំ២០១៧នេះ ការទិញចូលប្រាក់ដុល្លារបានថយចុះបន្តិច គឺមានចំនួនប្រមាណ ១៥៨,៩លានដុល្លារ។

*ផ្នែកទីផ្សារមូលបត្រ៖* ក្នុងខែមិថុនា ឆ្នាំ២០១៧ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជាមានចំនួន ៣.១៥ពាន់លានរៀល គឺបានលោតឡើងខ្ពស់ធៀបនឹងបណ្តាខែកន្លងទៅ, ក្នុងនោះតម្លៃជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ(PPSP) មាន ២.៣៧ពាន់លានរៀល និងក្រុមហ៊ុនកំពង់ផែស្វយ័តភ្នំពេញ(PPAP) មាន ៥៣១លានរៀល។

៣. *ការនាំចូល÷* ក្នុងខែឧសភា ឆ្នាំ២០១៧ ការនាំចូលគិតជាទឹកប្រាក់សរុប ១.១៨០លានដុល្លារ បានកើនឡើង ៩,៧%ធៀបនឹងខែមុន ក្នុងនោះការនាំចូលមុខទំនិញវាយនភ័ណ្ឌបានកើនឡើង ២២,៣%, ការនាំចូលមុខទំនិញប្រភេទផ្សេងៗបានកើនឡើង ៧,២%, ការនាំចូលបរិក្ខារសំណង់បានថយចុះ ១១%, និងការនាំចូលប្រេងឥន្ធនៈពុំមានការប្រែប្រួលគួរកត់សម្គាល់ទេធៀបនឹងខែកន្លងទៅ។ *ការនាំចេញ÷* ខែឧសភា ឆ្នាំ២០១៧ ការនាំចេញមានចំនួន ៨០៨លានដុល្លារ បានកើនឡើង ១៨,៤%ធៀបនឹងខែមុន, ក្នុងនោះផលិតផលវាយនភ័ណ្ឌនិងស្បែកជើងនាំចេញមានចំនួន ៥៥៦លានដុល្លារ បានកើនឡើង ១៧,២% និងផលិតផលអង្ករនិងកៅស៊ូនាំចេញក៏មានការកើនឡើងផងដែរបន្ទាប់ពីបានថយចុះក្នុងខែមេសាកន្លងទៅ។ រយៈពេល៥ខែ ឆ្នាំ២០១៧នេះ ការនាំចូលសរុបមានចំនួន ៥.៤៥៧លានដុល្លារ បានកើនឡើង ៨,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន និងការនាំចេញសរុបមានចំនួន ៤.០២១លានដុល្លារ បានកើនឡើង ៤,៧%។

៤. ក្នុងខែឧសភា ឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសសរុបបានចំនួន ១.៣៨០ប៊ីលានរៀល បានកើនឡើង ១,៣៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន គាំទ្រដោយចំណូលពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម អាករពិសេស និងចំណូលមូលធន។ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយថវិការសរុប ១.២០៦ប៊ីលានរៀល បានកើនឡើង ២០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយសារកំណើនឡើងនៃចំណាយមិនមែនបៀវត្ស។ តុល្យភាពថវិកាចរន្តសម្រាប់ខែឧសភា ឆ្នាំ២០១៧ មានអតិរេកសាច់ប្រាក់ ៤៣៣ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ១៧៤ប៊ីលានរៀល។

ជារួមក្នុងរយៈពេល ៥ខែដើមឆ្នាំ២០១៧នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបានចំនួន ៧.១៩៦ប៊ីលានរៀល បានកើនឡើង ១៥,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (ខ្ពស់ជាងច្បាប់ថវិកា ៤,៣%) ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានពន្ធដារកើនឡើង ៣៥,១%, ដែលនេះបានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃកំណែទម្រង់លើការចុះបញ្ជីអ្នកជាប់ពន្ធ សេវាកម្មដល់អ្នកជាប់ពន្ធ សវនកម្មសហគ្រាស ការប្រមូលបំណុលពន្ធ និងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ។ រយៈពេល ៥ខែដើមឆ្នាំនេះ ចំណាយថវិការដ្ឋបាលថ្នាក់ជាតិអនុវត្តសរុបចំនួន ៥.១១០ប៊ីលានរៀល (ទាបជាងច្បាប់ថវិកា ១៥,៥%) បានកើនឡើង ១៨,៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយមានកំណើនចំណាយសម្រាប់វិស័យការពារនិងសន្តិសុខជាតិនិងរដ្ឋបាលស៊ីវិល។ ជាលទ្ធផលរយៈពេល៥ខែដើមឆ្នាំ២០១៧នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៣.៥១៤ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ ២.០៨៥ប៊ីលានរៀល។

៥. ក្នុងខែឧសភា ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន ៧គម្រោង អាចបង្កើតការងារបានប្រមាណ ៧ពាន់នាក់ និងគិតជាទុនវិនិយោគ ១.០០៤លានដុល្លារ, ក្នុងនោះមានគម្រោងវិនិយោគក្នុងផ្នែកវិស័យសេវាកម្មរបស់ក្រុមហ៊ុនចិនសាងសង់ព្រលានយន្តហោះថ្មីនៅក្រុងសៀមរាបដែលមានទុនវិនិយោគ ៩៦២ លានដុល្លារ។ សរុបរយៈពេល៥ខែ ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគដែលបានអនុញ្ញាតមាន ៣៤គម្រោង គិតជាទុនវិនិយោគស្មើនឹង ១.១៦៥លានដុល្លារ បានថយចុះ ៣៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ក្នុងនោះមានការថយចុះខ្លាំងនូវការវិនិយោគលើវិស័យកសិកម្ម ឧហ្សាហកម្មនិងទេសចរណ៍ រីឯវិនិយោគវិស័យសេវាកម្មបានកើនឡើង ១៧៩%។

៦. ក្នុងខែឧសភា ឆ្នាំ២០១៧ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានប្រមាណ ៣៦៩ពាន់នាក់ បានថយចុះ ១០,៧% ធៀបនឹងខែមីនាកន្លងទៅ ប៉ុន្តែខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ១៥,០%, ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានបម្រែបម្រួលជាលក្ខណៈរដូវកាលដោយមានកម្រិតទាបក្នុងខែឧសភាដោយសារលក្ខណៈអាកាសធាតុ ហើយនឹងមានកំណើនឡើងបន្តិចមកវិញក្នុង

ខែកក្កដានិងសីហាខាងមុខ។ រយៈពេល៥ខែ ឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុបមាន ២.២៨៥ពាន់នាក់ បានកើនឡើង ១២,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៧. ក្នុងរយៈពេល៥ខែ ឆ្នាំ២០១៧នេះ សំណើសាងសង់សរុបមាន ១.២៤០គម្រោង បានកើនឡើង ២៥០គម្រោង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ប៉ុន្តែគិតជាផ្ទៃក្រឡាសាងសង់សរុបមាន ៤.៨៧១ពាន់ម៉ែត្រការ៉េ គឺបានថយចុះ ៥១% និងគិតជាតម្លៃសាងសង់សរុប ៤.៣៦២លានដុល្លារ បានថយចុះ ៣៤%។ ទោះមានការថយចុះនូវផ្ទៃក្រឡាសាងសង់សរុប ក្នុងរយៈពេល៥ខែដើមឆ្នាំនេះក្តី ក៏សំណង់នៃផ្នែកទេសចរណ៍មានការកើនឡើងខ្ពស់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំកន្លងទៅ។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែមិថុនា ឆ្នាំ២០១៧ ថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិជារួមមានការថយចុះធៀបនឹងខែមុន ដោយបានថយចុះខ្លាំងក្នុង៣សប្តាហ៍ដំបូង និងបានកើនឡើងបន្តិចមកវិញក្នុងសប្តាហ៍ចុងក្រោយនៃខែ។ យោងតាមភ្នាក់ងារអង្កេតថ្លៃប្រេងអន្តរជាតិOilSNSរបស់ប្រទេសចិន ការធ្លាក់ចុះនៃថ្លៃប្រេងឆៅក្នុងខែមិថុនានេះ គឺដោយសារកំណើនខ្ពស់នៃបរិមាណប្រេងស្តុករបស់សហរដ្ឋអាមេរិក និងការព្យាកររបស់ភ្នាក់ងារថាមពលអន្តរជាតិIEAរំពឹងថាបរិមាណផ្គត់ផ្គង់ប្រេងក្នុងឆ្នាំ២០១៨អាចនឹងមានកំណើនខ្ពស់។ នៅចុងខែមិថុនានេះ តម្លៃប្រាក់ដុល្លារអាមេរិកបានថយចុះបន្តិច ទិន្នផលផលិតកម្មប្រេងរបស់អាមេរិកមានការថយចុះ និងបរិមាណស្តុកនៃប្រេងឆៅនិងប្រេងសាំងរបស់អាមេរិកក៏បានថយចុះបន្តិចមកវិញផងដែរ។

*ថ្លៃអង្ករ* ក្នុងខែមិថុនា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤២០ដុល្លារ/តោន បានរក្សាតម្លៃថេរធៀបនឹងខែមុននិង១ឆ្នាំមុន។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤៥៨ដុល្លារ/តោន បានកើនឡើង ៨,៨% ធៀបនឹងខែមុន និងកើនឡើង ៣,៩% ធៀបនឹង១ឆ្នាំមុន។ ប្រទេសថៃបាននាំចេញអង្ករ ៥លានតោនក្នុងរយៈពេល ៥ខែដើមឆ្នាំ២០១៧នេះ ហើយរំពឹងថានឹងសម្រេចបានគោលដៅនាំចេញអង្ករ ១១លានតោនសម្រាប់ឆ្នាំ២០១៧នេះ, ម្យ៉ាងទៀតរាជរដ្ឋាភិបាលថៃបាន និងកំពុងសិក្សាដើម្បីចាត់វិធានការលើកស្ទួយតម្លៃកសិផលសម្រាប់រដូវកាលប្រមូលផលខាងមុខ។ *(៣)អង្កវៀតណាម* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៥៧ដុល្លារ/តោន បានកើនឡើង ៣,៥% ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ៤,១% បើធៀបនឹង១ឆ្នាំមុន។ រដ្ឋាភិបាលវៀតណាមបានអនុម័តដាក់ចេញយុទ្ធសាស្ត្រថ្នាក់ជាតិដើម្បីកាត់បន្ថយបរិមាណនាំចេញនិងលើកកម្ពស់តម្លៃអង្ករ ចាប់ពីឆ្នាំ២០១៧ ដល់ ២០២០, ក្នុងនោះគោលដៅនាំចេញ ៦០% គឺទៅកាន់ទីផ្សារតំបន់អាស៊ី, ២២% ទៅកាន់ទ្វីបអាហ្វ្រិក និង១៨% ទៅកាន់តំបន់ផ្សេងៗទៀត។

*ថ្លៃកៅស៊ូ* ក្នុងខែមិថុនា ឆ្នាំ២០១៧នេះ ថ្លៃកៅស៊ូធម្មជាតិជារួមមានការថយចុះធៀបនឹងខែកន្លងទៅ, គិតត្រឹមខែមិថុនានេះ កៅស៊ូស្តង់ដារSTR20ថ្លៃ ១.៤៤០ដុល្លារ/តោន បានថយចុះ ៥,៩% ធៀបនឹងខែមុន និងកៅស៊ូSGP/MYSថ្លៃ ១.៧២០ដុល្លារ/តោន បានថយចុះ ១៨,០%។ យោងតាមរបាយការណ៍ភ្នាក់ងារសេវាកម្មអំពីទំនិញបឋមអន្តរជាតិ(JLC)របស់ប្រទេសចិន បរិមាណផ្គត់ផ្គង់កៅស៊ូសំយោគមានការកើនឡើងក្នុងខែមិថុនានេះ, រីឯផលិតកម្មកង់ឡានក្នុងខែខាងមុខនឹងមានការថយចុះជាលក្ខណៈរដូវកាល។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Construction Approval in Nationwide (0000m2)**




Source: Min. LMUC

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណានិងទុនបំរុងបរទេស (Inflation and Foreign Reserves)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Min-lending & 3month deposit Interest rate in Riel**




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchange rate R/100Đ and R/B**




Source: IMF

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)


















# ការអនុវត្តថវិកា (Budget)

### ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧




### ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧




### ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧




Source: MEF

### ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧




### ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧




### ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs Dept.

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

********

**រៀបចំដោយ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧៩១៣, ០៧៧ ៧០៣៤៣៦, ០៩៦ ៩៧៩១៦៨៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*